“ឯកសារនេះគឺជាការបកប្រែនៃឯកសារពេញច្បាប់ដែល HUD បានចេញផ្សាយ ។ HUD ផ្តល់ការបកប្រែនេះជូនអ្នក គឺគ្រាន់តែជាការងាយស្រួល ដើម្បីជួយអ្នកឲ្យយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប៉ុណ្ណោះ ។ កំណែជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាឯកសារផ្លូវការ ពេញច្បាប់ និង ជាឯកសារត្រួតត្រា ។ ឯកសារដែលបានបកប្រែនេះ គឺមិនមែនជាឯកសារផ្លូវការឡើយ” ។

---

# ភស្តុតាង 7-1: **គំរូ** ការបញ្ជាក់សាថ្មីជាប្រចាំឆ្នាំ លិខិតដើមដំបូង

[ត្រូវបានចុះហត្ថលេខាដោយអ្នកមូលដ្ឋាន និងម្ចាស់ផ្ទះ នៅពេលការបញ្ជាក់ជាលើកដំបូង និងការបញ្ជាក់សាថ្មីជាបន្តបន្ទាប់ទៀត / To be signed by resident and owner at initial certification and at subsequent recertifications] ។

(ឈ្មោះរបស់អ្នកជួលផ្ទះ Tenant’s Name) (ខែថ្ងៃឆ្នាំ / Date)
(អាសយដ្ឋាន / Address)

ជូនចំពោះ _______________:

ដូចបានថ្លែងក្នុងវគ្គ [15, 10, ឬ 9—បញ្ជាក់លេខវគ្គ ថាត្រូវគ្នានឹងវគ្គនៃគំរូកិច្ចសន្យាជួលដែលកំពុងបានប្រើ សំរាប់អ្នកជួលផ្ទះ / 15, 10 or 9—indicate the paragraph number that corresponds to the paragraph of the model lease being used for the tenant] នៃកិច្ចសន្យាជួល របស់អ្នក ថាក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង (Department of Housing and Urban Development - HUD) សហរដ្ឋ តម្រូវឲ្យយើង ពិនិត្យមើលឡើងវិញ នូវប្រាក់ចំណូល និងទំហំគ្រួសាររបស់អ្នក ជារៀងរាល់ឆ្នាំ ដើម្បីអនុម័តសាថ្មី នូវថ្លៃជួលផ្ទះ និងកំរិតជំនួយ ។

ដើម្បីបំពេញការពិនិត្យមើលឡើងវិញ នូវប្រាក់ចំណូល និងទំហំគ្រួសាររបស់អ្នក អ្នកត្រូវតែជួបជាមួយនឹង (អ្នកចាត់ចែងអ្នកមូលដ្ឋាន, ស្មៀនខាងការរស់នៅ ជាដើម / Resident Manager, Occupancy Clerk, etc.) ព្រមទាំងនឹងផ្តល់ព័ត៌មានដែលបានតម្រូវ រៀងរាល់ឆ្នាំ ។ (អ្នកចាត់ចែងអ្នកមូលដ្ឋាន, ស្មៀនខាងការរស់នៅ ជាដើម / Resident Manager, Occupancy Clerk, etc.) នឹង ធ្វើសំភាសការបញ្ជាក់សាថ្មីរបស់អ្នក ក្នុង (ខែនិងឆ្នាំ / month and year) ។ យើងនឹងផ្ញើលិខិតរំលឹកអ្នក នៅពេលវាដល់ពេល សំរាប់ធ្វើសំភាសការបញ្ជាក់សាថ្មីរបស់អ្នកនៅលើកក្រោយ ។ នៅពេលនោះ អ្នកត្រូវតែទាក់ទង (អ្នកចាត់ចែងអ្នកមូលដ្ឋាន, ស្មៀនខាងការរស់នៅ ជាដើម / Resident Manager, Occupancy Clerk, etc.) ដើម្បីគ្រោងពេល វេលាការណាត់ជួប សំរាប់ការសំភាសន៍ ។

**សេចក្តីតម្រូវនៃការសហការជាមួយនឹងការបញ្ជាក់សាថ្មី គឺជាលក្ខខ័ណ្ឌនៃការចូលរួមក្នុងកម្មវិធីជាបន្តទៀត ។ អ្នកត្រូវតែរាយការណ៍ព័ត៌មានដែលបានតម្រូវ និងចុះហត្ថលេខាដែលបានតម្រូវ ដើម្បីឲ្យម្ចាស់ផ្ទះអាចពិនិត្យការបញ្ជាក់សាថ្មី នៅ (បញ្ចូលថ្ងៃទី 10 នៃខែ 11 បន្ទាប់ពីការបញ្ជាក់សាថ្មីជាប្រចាំឆ្នាំលើកចុងក្រោយបង្អស់/ insert the 10th day of the 11th month after the last annual recertification) ។ **

នៅពេលអ្នកមកជួបធ្វើសំភាស អ្នកត្រូវតែយកព័ត៌មាននៅខាងក្រោមមកជាមួយ : (កត់ព័ត៌មានទាំងអស់ដែលបានតម្រូវ / list all required information) ។

ខ្ញុំបានអាន និងយល់ដឹងសេចក្តីសំបុត្រនេះ ដែលរៀបរាប់សេចក្តីតម្រូវសំរាប់ការចូលរួមរបស់ខ្ញុំ ក្នុងការសំភាសន៍ការបញ្ជាក់សាថ្មីជាប្រចាំឆ្នាំ ។

**“តែកំណែកិច្ចសន្យាជួលជាភាសាអង់គ្លេសប៉ុណ្ណោះទេ ដែលត្រូវបានចុះហត្ថលេខា” ។**